## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៤
## នៅទីស្តីការគណៈរដ្ឋមន្ត្រី
## ថ្ងៃអង្គារ ៥ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
## ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងកិច្ចប្រជុំនាពេលនេះ!

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមជាមួយនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈសមស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះ ដែលខ្ញុំសូមសង្ខេបជូនដូចតទៅ ៖

- ទី១ : ការជំរុញអនុវត្តគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ ។
- **ទី២** : ការអនុម័ត សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៤ សម្រាប់បន្តអនុវត្តក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្ពោះទៅសម្រេចបាននូវគោលដៅ ៩៥-៩៥-៩៥ ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្តល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព រយៈពេល៦ខែដើមឆ្នាំ២០២៤ ទៅតាមក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២) ចូលរួមទាំងអស់គ្នាដើម្បីពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំ ជាមួយអាទិភាពដែលមានចែងនៅក្នុងយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទីមួយ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គោលនយោបាយ ឬផែនការតាមវិស័យ និងកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល។

៣) ខ្ញុំសូមលើកទឹកចិត្តជូនគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ឱ្យបន្តជំរុញ និងចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ និងការប្រើប្រាស់ កញ្ចប់ថវិកា ៨០ លានរៀល ៦០ លានរៀល និង ៤០ លានរៀល បានចំគោលដៅ សំដៅលើកកម្ពស់ស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពនៃការឆ្លើយតបនឹងជំងឺអេដស៍។

៤) បង្កើនប្រសិទ្ធភាព នៃភាពជាដៃគូប្រកបដោយបរិយាបន្នជាមួយ ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍជាពិសេសបន្តសហការជាមួយ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងផែនការ ក្រសួងសង្គមកិច្ច និងក្រសួងសុខាភិបាល ដើម្បីបន្តផ្តល់នូវអត្ថប្រយោជន៍គាំពារសង្គម គាំទ្រដល់ការងារឆ្លើយតបនឹងការរាលដាលមេរោគអេដស៍ ជំងឺអេដស៍ដល់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែលម្អសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពនាពេលខាងមុខ។

២) ជំរុញ និងប្រើប្រាស់គ្រប់យន្តការទាំងអស់ ដើម្បីធ្វើឱ្យសម្រេចបានជោគជ័យក្នុងការអនុវត្តគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨ ។

៣) ប្រឹងប្រែងអនុវត្តសេចក្តីសម្រេចចិត្តនៃសម័យប្រជុំពេញអង្គ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៤ ដែលទើបបានទទួលការអនុម័តនាពេលនេះ។

៤) បន្តជំរុញ និងលើកទឹកចិត្តក្រសួង ស្ថាប័ន ដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យលើកសំណើថវិកាឆ្នាំ២០២៥ ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួង ស្ថាប័នសាមីឱ្យបានព្រមៗគ្នា។

៥) លើកទឹកចិត្តប្រជាជនគន្លឹះ ឱ្យមកធ្វើតេស្តឈាមរកមេរោគអេដស៍ ឱ្យបានច្រើនជាទីបំផុត។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ។ ការចូលរួមយ៉ាងសកម្ម ដោយផ្តល់នូវគំនិត យោបល់ល្អៗ និងមានតម្លៃនាំឱ្យយើងអាចយកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺ អេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះ ឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់នូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ខ្ញុំសូមប្រកាសបិទ “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៤**” ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***